ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧ អនក្រ.បក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ៥៩៧
ថ្ងៃទី ០៤.០៧.១៤
បញ្ជូន

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការគ្រប់គ្រង តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើត បង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ការរៀបចំ និងការគ្រប់គ្រង តំបន់រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ។

**មាត្រា ២ .-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ៖

- រក្សាតំលៃលេចធ្លោជាសកល នៃបេតិកភណ្ឌពិភពលោកប្រាសាទព្រះវិហារ និងតំបន់ជុំវិញ។
- អភិរក្ស និងលើកតម្លៃកេរដំណែលវប្បធម៌ បុរាណវិទ្យា ជាតិពន្ធុវិទ្យា និងធនធានធម្មជាតិ។
- ធានាការអភិវឌ្ឍតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រកបដោយចីរភាព។
- ជំរុញផលិតកម្មកសិកម្មធម្មជាតិ ការប្រើប្រាស់ថាមពលកកើតឡើងវិញ ការអភិវឌ្ឍទេសចរណ៍វប្បធម៌ និងធម្មជាតិស្របតាមផែនការគ្រប់គ្រងដែលទទួលស្គាល់ដោយអង្គការយូណេស្កូ និងផែនការគ្រប់គ្រងតំបន់ប្រាសាទព្រះវិហារ។

**មាត្រា ៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើរាល់តំបន់ការពារតាមប្លង់កំណត់ ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ។

**មាត្រា ៤ .-**

ការរៀបចំចាត់ចែង និងគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ជាសមត្ថកិច្ចរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ (អ.ជ.ព.វ) ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/០៦០៦/២៤៨ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ដោយមានកិច្ចសហការជិតស្និទ្ធ និងជាប្រចាំជាមួយអាជ្ញាធរដែនដី និងអង្គភាពពាក់ព័ន្ធ។

## ជំពូកទី ២

## ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍ

### ផ្នែកទី ១

### ការគ្រប់គ្រងតំបន់ប្រាសាទព្រះវិហារ

**មាត្រា ៥ ៈ-**

រាល់កិច្ចអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង៤ (បួន ) អ.ជ.ព.វ ត្រូវៈ

- រៀបចំបទដ្ឋានគតិយុត្ត សម្រាប់ពិនិត្យ វាយតម្លៃ និងអនុម័តគម្រោងអភិវឌ្ឍន៍នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ។

- ធានាថារាល់គម្រោងអភិវឌ្ឍន៍ ត្រូវបានគិតគូរអំពីផលប៉ះពាល់បរិស្ថាន ជនជាតិភាគតិច និងប្រជាជនមូលដ្ឋាន ដោយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានអោយមានកម្រិតទាបបំផុត ។

- បញ្ចូលការវាយតម្លៃផលប៉ះពាល់បរិស្ថាន ក្នុងការស្រាវជ្រាវបុរាណវិទ្យា នៅតំបន់ពាក់ព័ន្ធទាំងនោះ។

- ធ្វើកំណាយសង្គ្រោះផ្នែកបុរាណវិទ្យា ដើម្បីប្រមូលទិន្នន័យផ្នែកបុរាណវិទ្យា និងវត្ថុបុរាណមករក្សាទុកមុននឹងចាប់ផ្តើមអនុវត្តគម្រោងអភិវឌ្ឍន៍ ។

**មាត្រា ៦ ៈ-**

- ការអភិវឌ្ឍរមណីយដ្ឋានក្នុងតំបន់១ ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណាដែលមានសារប្រយោជន៍សម្រាប់កិច្ចការអភិរក្ស ការលើកស្ទួយតម្លៃនៃរមណីយដ្ឋានប្រាសាទព្រះវិហារ និងការចូលរួមពីប្រជាជនស្របតាមផែនការគ្រប់គ្រងតំបន់។

-ការអភិវឌ្ឍក្នុងរមណីយដ្ឋានតំបន់២ ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណាដែលមានសារប្រយោជន៍ សម្រាប់កិច្ចការអភិរក្ស ទេសចរណ៍ និងការលើកស្ទួយតម្លៃនៃស្ថានីយ៍បុរាណវិទ្យាបរិស្ថានធម្មជាតិ។

**មាត្រា៧ ៈ-**

- រាល់កិច្ចអភិវឌ្ឍន៍ក្នុងរមណីយដ្ឋានវប្បធម៌ធម្មជាតិក្នុងតំបន់ ៣ អ.ជ.ព.វ និង អាជ្ញាធរខេត្តព្រះវិហារ ត្រូវកំណត់ប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី ដោយតម្រង់ទិសដៅអភិវឌ្ឍន៍ដោយចីរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- រាល់ការផ្តល់លិខិតអនុញ្ញាតសាងសង់ និងរុះរើ ត្រូវចេញដោយ អ.ជ.ព.វ សហការជាមួយអាជ្ញាធរដែនដី។

- ចំពោះទីតាំងដែលសង្ស័យថាមានសំណល់បុរាណវិទ្យា ស្ថាប័នមានសមត្ថកិច្ចត្រូវសុំកិច្ចសហការពី អ.ជ.ព.វ មុនចេញប័ណ្ណកម្មសិទ្ធិដីធ្លី។

- ការអភិវឌ្ឍក្នុងតំបន់ ៤ ត្រូវបានកំណត់សម្រាប់តែការអភិវឌ្ឍន៍ណាដែលមានសារប្រយោជន៍ដល់សហគមន៍មូលដ្ឋាន។

**មាត្រា ៨ ._**

- រាល់ការអភិវឌ្ឍ សំណង់នានាក្នុងតំបន់ ១ និងក្នុងតំបន់ ២ ត្រូវហាមឃាត់លើកលែងតែការអភិវឌ្ឍសំណង់ណាដែលចាំបាច់ ហើយត្រូវបានកំណត់ និងអនុញ្ញាតដោយ អ.ជ.ព.វ។

- តំបន់ ៣ ៖ ជាតំបន់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ រាល់ការប្រើប្រាស់ដីធ្លីដែល មានលក្ខណៈជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវមានការឯកភាពពី អ.ជ.ព.វ ដោយមានការចូលរួមពីស្ថាប័នមានសមត្ថកិច្ច។

- អ.ជ.ព.វ និងស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំបទដ្ឋានបច្ចេកទេស ប្រភេទនៃការប្រើប្រាស់ដី និងសំណង់នៅក្នុងតំបន់(៣ក) និង(៣ខ)។

- តំបន់ ៣ (ក) នេះជាគោលដៅថែរក្សាវប្បធម៌ និងធម្មជាតិតាមរយៈការចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍឲ្យមានចីរភាព និងមានការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងទេសភាពវប្បធម៌ធម្មជាតិ។

- តំបន់ ៣ (ខ) មិនអនុញ្ញាតចំពោះសំណង់ និងការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារដែលបង្កជាអគ្គីភ័យ បាត់បង់សោភ័ណភាព បំពុលបរិស្ថាន និងជាគំរបព្រៃឈើ។ អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់កម្មសិទ្ធិជូនប្រជាជនក្នុងចំងាយ ៥០ ម៉ែត្រពីអ័ក្សផ្លូវជាតិលេខ ៦២ ហើយមិនត្រូវលើសពី ១០០០ ម៉ែត្រពីអ័ក្សផ្លូវ។

- ចំពោះតំបន់ ៣ (ខ) ដែលជាប់នឹងព្រំប្រទល់ភូមិធម្មជាតិស្របផ្លូវជាតិលេខ ៦២ ចាប់ពីនិយាមការ (ក) X:0469904, Y:1575218 ; (ខ) X:0468675, Y:1575219 ; (គ) X:0468672, Y:1578459 ; (ឃ) X:0469357 Y:1578459 រួមនឹងព្រំប្រទល់ខាងត្បូងភូមិធម្មជាតិចំងាយ ១៧០ ម៉ែត្រ ពីអ័ក្សផ្លូវក្រវ៉ាត់ភូមិខាងត្បូងគឺត្រូវរក្សាជាខ្សែក្រវ៉ាត់បៃតង និងដាំដុះព្រៃឈើឡើងវិញ ហើយត្រូវទុកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋគ្រប់គ្រងដោយ អ.ជ.ព.វ ដូចបានកំណត់ក្នុងផែនទីកំណត់ព្រំប្រទល់ និងបែងចែកតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ដែលជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ។

- តំបន់ ៤ ៖ ជាតំបន់អភិវឌ្ឍន៍សហគមន៍មូលដ្ឋាន និងការអភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ។ រាល់ការប្រើប្រាស់ដីនៅតំបន់នេះត្រូវមានការអនុញ្ញាតពី អ.ជ.ព.វ និងអាជ្ញាធរខេត្តព្រះវិហារ។

## ផ្នែកទី ២
## អំពីបុរាណវិទ្យា

**មាត្រា ៩ ._**

ក្នុងសកម្មភាពបុរាណវិទ្យា នៅក្នុងរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង៤ អ.ជ.ព.វ ត្រូវ ៖

- រៀបចំកម្មវិធីលំអិត ដើម្បីសម្រង់ព័ត៌មានបុរាណវត្ថុ នៅតំបន់ប្រាសាទព្រះវិហារ និងតំបន់ជុំវិញ។

- ធ្វើបញ្ជីសារពើភណ្ឌគ្រប់ទីតាំងបុរាណវត្ថុនៅតំបន់ប្រាសាទព្រះវិហារ និងតំបន់ជុំវិញ ហើយបញ្ចូលបញ្ជីនោះ ទៅក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ។ កំណត់លក្ខណៈវិនិច្ឆ័យព្រមទាំងកម្មវិធីសម្រាប់សំគាល់ស្ថានីយ៍ណាដែលជាចំណុចមានសារប្រយោជន៍ផ្នែកបុរាណវិទ្យា ជាតិពន្ធុវិទ្យា នរវិទ្យា និងប្រវត្តិវិទ្យា។

- រៀបចំទិសដៅ និងគំរូកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយដៃគូអភិរក្សសម្រាប់ចាត់ចែងគ្រប់គ្រងស្ថានីយ៍ទាំងអស់នោះក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា និងអប់រំ។

- រកគ្រប់មធ្យោបាយជំរុញការងារអភិរក្ស ជួសជុលប្រាសាទ និងហេដ្ឋារចនាសម្ព័ន្ធបុរាណ។

- ជំរុញការផ្សព្វផ្សាយ ការស្រាវជ្រាវ និងលើកតំលៃផ្នែកបុរាណវត្ថុវិទ្យា ជាតិពន្ធុវិទ្យា ស្ថាបត្យកម្ម និងប្រវត្តិវិទ្យា។

- កំណត់លក្ខណៈវិនិច្ឆ័យ និងកម្មវិធីការងារសម្រាប់សំគាល់ទេសភាពវប្បធម៌ត្រូវការពារ។

- កំណត់ទិសដៅនយោបាយ ដើម្បីចាត់ចែងគ្រប់គ្រងទេសភាពវប្បធម៌ទាំងអស់នោះក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា និងផ្នែកអប់រំ។

- ដាក់អោយមានសន្តិសុខអភិរក្ស ឬឆ្មាំ ដើម្បីថែទាំ និងការពារស្ថានីយ៍នីមួយៗ។

**មាត្រា ១០ .-**

- អ.ជ.ព.វ ត្រូវការពារយ៉ាងមធ្យ័តបរិវេណរមណីយដ្ឋានមានប្រាសាទក្នុងតំបន់១ ហើយគ្រប់គ្រងបរិវេណទាំងនោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬ លំហែកំសាន្ត។

- អ.ជ.ព.វ ត្រូវរៀបចំទីតាំងយុទ្ធសាស្ត្របំរើការងារអន្តរាគមន៍បន្ទាន់សំរាប់ការងារជួសជុល និងការងារអភិរក្សប្រាសាទ។

**មាត្រា ១១ .-**

អ.ជ.ព.វ ត្រូវ ៖

- ការពារយ៉ាងមធ្យ័ត និងលើកតំលៃសំណល់វប្បធម៌ ព្រមទាំងសំណល់ស្ថានីយ៍បុរាណវិទ្យាទាំងអស់ដែលស្ថិតនៅលើដី ឬក្រោមដី។ រាល់ការជីកកកាយ ជីកយកអាចម៍ដី និងការចាក់បំពេញ ឬលុបដី ត្រូវមានការពិនិត្យ និងអនុញ្ញាតពី អ.ជ.ព.វ។

- ត្រួតពិនិត្យ និងគ្រប់គ្រងរាល់សកម្មភាពនានា ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានដល់ស្ថានីយ៍បុរាណវិទ្យាទាំងអស់នោះ ។

**មាត្រា ១២ .-**

ក្នុងការស្រាវជ្រាវ ឬការប្រទះឃើញដោយចៃដន្យនូវរចនាសម្ព័ន្ធប្រាសាទ ដូចជា ៖ ឃឿនប្រាសាទ តួប្រាសាទ កសិណ ស្រះបុរាណ បារាយណ៍ ស្ពាន ផ្លូវបុរាណ ជាដើម ទោះស្ថិតក្នុងតំបន់ណាក៏ដោយ នឹងត្រូវបានកំណត់ចំងាយបរិវេណជុំវិញនោះតាមទំហំ និងស្ថានភាពជាក់ស្តែងដោយអ្នក

ជំនាញ អ.ជ.ព.វ ហើយនឹងត្រូវកំណត់ជាតំបន់ត្រូវការពារពិសេសដូចតំបន់ ១ ដែរ។

## ផ្នែកទី ៣
## ការគ្រប់គ្រងទេសចរណ៍ និងអ្នកស្រាវជ្រាវ

**មាត្រា ១៣ .-**

ក្នុងការគ្រប់គ្រងទេសចរណ៍ និងអ្នកស្រាវជ្រាវ នៅរមណីយដ្ឋានប្រាសាទព្រះវិហារ ក្នុងតំបន់ទាំង៤ អ.ជ.ព.វ ត្រូវ ៖

- គ្រប់គ្រងការចេញ-ចូល របស់ភ្ញៀវទេសចរ និងអ្នកស្រាវជ្រាវ ដែលមានគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ទស្សនាចរ ធនធានរ៉ែ និងសហគមន៍ជនជាតិភាគតិច។

- រៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងសេវាកម្មទេសចរណ៍ ខ្សែទស្សនាចរ កម្មវិធីវិនិយោគទេសចរណ៍។

- ទប់ស្កាត់រាល់សកម្មភាពបង្ករការប៉ះពាល់ដល់តម្លៃរមណីយដ្ឋាន និងបរិស្ថានដែលបណ្តាលមកពីទេសចរ និងអ្នកស្រាវជ្រាវរួមទាំងសាធារណជនទូទៅ។

- កំណត់តម្លៃប័ណ្ណទស្សនា ដោយមានការពិភាក្សា ឯកភាពជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីប្រមូលចំណូលជូនរដ្ឋសម្រាប់យកមកអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋាននោះយកមកថែរក្សា និងចាត់ចែងគ្រប់គ្រងរមណីយដ្ឋាននោះ។

- កំណត់តម្លៃសេវាកម្មនូវរាល់សកម្មភាពពាណិជ្ជកម្មដូចជា ថតផ្សាយពាណិជ្ជកម្ម ពិធីជប់លៀង ពិធីសម្តែងសិល្បៈ ទស្សនីយភាព ថតខ្សែភាពយន្ត សេវាកម្មដឹកជញ្ជូន និងសេវាកម្មចាំបាច់ផ្សេងៗទៀត។ល។

- រាល់លទ្ធផលនៃការសិក្សាស្រាវជ្រាវ បុរាណវត្ថុវិទ្យា ជាតិពន្ធុវិទ្យា ស្ថាបត្យកម្ម និង ប្រវត្តិវិទ្យា ដោយអ្នកវិទ្យាសាស្ត្រ ត្រូវមានការបោះពុម្ពផ្សាយ ដោយមានការត្រួតពិនិត្យពី អ.ជ.ព.វ ហើយត្រូវរក្សាជាសិទ្ធិបេតិកភណ្ឌរបស់អ្នកស្រាវជ្រាវក្នុងរយៈពេល ០៥ឆ្នាំ។ ក្រោយផុតអាជ្ញាយុកាលនៃ សិទ្ធិបេតិកភណ្ឌនេះ លទ្ធផលនៃការស្រាវជ្រាវ និងការបោះពុម្ពផ្សាយត្រូវរក្សាទុកជាកម្មសិទ្ធិរបស់ អ.ជ.ព.វ សំរាប់ប្រើប្រាស់ក្នុងផលប្រយោជន៍សាធារណៈ។

**មាត្រា ១៤ .-**

ក្នុងការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់ប្រាសាទ អ.ជ.ព.វ ត្រូវ ៖

- កំណត់ និងរៀបចំការចេញ-ចូលទស្សនាតាមបែបបទ។

- ដាក់ឲ្យមានជាប្រចាំនូវមន្ត្រីរបស់ អ.ជ.ព.វ ដើម្បីផ្តល់ព័ត៌មានណែនាំ ថែរក្សា សន្តិសុខ គុណភាពបរិស្ថាន និងផ្តល់សេវាផ្សេងៗដល់ទេសចរណ៍។

- កម្រិតចំនួន និងទំហំក្រុមភ្ញៀវទេសចរដើម្បីរក្សាគុណភាពទស្សនកិច្ច និងដើម្បីងាយស្រួលការពារប្រាង្គប្រាសាទ។

- កំណត់ប្រភេទ និងលក្ខណៈសម្បត្តិយានយន្តដែលត្រូវអនុញ្ញាតឲ្យចេញ-ចូល ក្នុងតំបន់អភិរក្ស និងតម្រូវឲ្យចូលចតក្នុងទីលានចំណតនៅទីតាំងបដិសណ្ឋារកិច្ចដែលបានកំណត់។

**មាត្រា ១៥ ._**

ក្នុងការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់ ២ អ.ជ.ព.វ ត្រូវ ៖

- កំណត់ទីតាំងទទួលភ្ញៀវទេសចរ និងទីលានចំណតនៅក្នុងតំបន់ទ្រនាប់។

- កសាងហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតសេវា សំរាប់បំរើឲ្យការអភិរក្ស និងការអភិវឌ្ឍទេសចរណ៍នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ។

## ផ្នែកទី ៤

## សំណង់ទេសចរណ៍

**មាត្រា ១៦ ._**

គ្រប់ការសាងសង់សំណង់ទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារត្រូវមានការអនុញ្ញាតពី អ.ជ.ព.វ និងប្រព្រឹត្តទៅតាមបទដ្ឋានបច្ចេកទេស សៀវភៅបន្ទុក និងបទបញ្ជារបស់ អ.ជ.ព.វ និងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា ១៧ ._**

អ.ជ.ព.វ អនុញ្ញាតឲ្យមានការរៀបចំទីលានបដិសណ្ឋារកិច្ចកំរិតមធ្យមដើម្បីបំរើសេវាកម្មទេសចរណ៍ដូចជា ៖ ចំណត សំណង់តូបលក់ដូរ បង្គន់អនាម័យសាធារណៈ អគាររង់ចាំ អគារសង្គ្រោះបឋម អគារផ្តល់ព័ត៌មាន មណ្ឌលព័ត៌មានស្រាវជ្រាវ និងអភិរក្ស។ល។

**មាត្រា ១៨ ._**

ក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវ ៖

- កាត់បន្ថយផលប៉ះពាល់អវិជ្ជមាន បណ្តាលមកពីការអភិវឌ្ឍទេសចរណ៍ទៅលើសហគមន៍រស់នៅទីនោះ។

- រៀបចំស្តង់ទេសចរណ៍ និងមជ្ឈមណ្ឌលសិប្បកម្ម ដើម្បីផ្តល់លទ្ធភាពផ្នែកសេដ្ឋកិច្ចដល់អ្នករស់នៅទីនោះ ។

- រៀបចំប្លង់គោលដែលមានទីលានបដិសណ្ឋារកិច្ច នៅតំបន់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ ដើម្បីបំរើសេវាកម្មទេសចរណ៍ដូចជា សារមន្ទីរ ឧទ្យានបូតានិច ពហុកីឡាដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងគម្រោងវិនិយោគ។

- លើកទឹកចិត្តឲ្យមានសាលារៀន សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាជនក្នុងសហគមន៍ មូលដ្ឋានឲ្យមានមុខជំនាញក្នុងផ្នែកទេសចរណ៍ កសិកម្ម បរិស្ថាន សិប្បកម្ម និងឧស្សាហកម្មខ្នាតតូច ដោយធានាអោយបាននូវសេវាកម្មល្អប្រសើរ។

## ផ្នែកទី ៥

## រមណីយដ្ឋានវប្បធម៌

**មាត្រា ១៩ .-**

រមណីយដ្ឋានវប្បធម៌ធម្មជាតិក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវ ៖

- រៀបចំផែនការដើម្បីបង្ហាញបុរាណវិទ្យា ជាតិពន្ធុវិទ្យា នរវិទ្យា ព្រមទាំងតំបន់ការពារធម្មជាតិ និងប្រពៃណីអ្នកស្រុកក្នុងតំបន់។

- បង្កើតមជ្ឈមណ្ឌលព័ត៌មាន និងវប្បធម៌នៅក្រៅរមណីយដ្ឋានត្រូវការពារដាច់ខាត ដើម្បីផ្តល់ជូនទស្សនិកជននូវការណែនាំស្តីពីបេតិកភណ្ឌប្រាសាទព្រះវិហារ ធនធានធម្មជាតិ និងប្រវត្តិសាស្ត្រក្នុងតំបន់។

**មាត្រា ២០ .-**

អ.ជ.ព.វ ត្រូវបង្កើតកម្មវិធីអប់រំដល់សិស្ស និងសហគមន៍ស្តីពីជីវភាពរស់នៅរបស់ប្រជាជន ទស្សនីយភាពផ្នែករបាំបុរាណ ប្រពៃណី ទំនៀមទំលាប់ ផលិតកម្ម សិប្បកម្ម និងទិដ្ឋភាពពិសេសៗ របស់រមណីយដ្ឋានប្រាសាទព្រះវិហារ។

## ផ្នែកទី ៦

## ការដ្ឋានយកថ្ម និងរ៉ែធម្មជាតិ

**មាត្រា ២១ .-**

ការធ្វើអាជីវកម្មយកថ្ម និងរ៉ែធម្មជាតិនៅរមណីយដ្ឋានប្រាសាទព្រះវិហារក្នុងតំបន់ទាំង៤ អ.ជ.ព.វ ត្រូវ ៖

- កំណត់ និងការពារការដ្ឋានជីកយកថ្មបាយក្រៀម និងថ្មភក់នៅក្នុងរមណីយដ្ឋានដែលត្រូវការពារសម្រាប់យកមកប្រើប្រាស់ក្នុងការជួសជុលបុរាណវត្ថុ និងប្រាង្គប្រាសាទ ក្រោយពីបានធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងបានការអនុញ្ញាតពី អ.ជ.ព.វ ។

- ហាមឃាត់ការជីកកកាយដីឥដ្ឋ ដីក្រហម ខ្សាច់ និងថ្មក្នុងរមណីយដ្ឋានដែលត្រូវការពារ។

## ផ្នែកទី ៧

## ការគ្រប់គ្រងទេសភាព ព្រៃឈើ និងទឹក

**មាត្រា ២២ .-**

ក្នុងការចាត់ចែងគ្រប់គ្រងទេសភាព ព្រៃឈើ និងទឹកនៅរមណីយដ្ឋានប្រាសាទព្រះវិហារក្នុងតំបន់ទាំង៤ អ.ជ.ព.វ ត្រូវ ៖

- ការពារ និងបង្កើនតម្លៃទេសភាពវប្បធម៌គ្រប់ការអភិវឌ្ឍ។

- បញ្ចូលទៅក្នុងផែនការ និងសកម្មភាពនៃការចាត់ចែងគ្រប់គ្រងរមណីយដ្ឋាននូវគោលនយោបាយ និងទិសដៅសម្រាប់ការចាត់ចែងគ្រប់គ្រងទេសភាព ។

- ការពារដាច់ខាតគំរបព្រៃបៃតងក្នុងទីប្រជុំជន និងតាមសងខាងដងអូរធម្មជាតិចំងាយ ១៥០ ម៉ែត្រ ជាព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ។

- រាល់ការដាក់ស្លាកសញ្ញា និងបិតផ្សាយពាណិជ្ជកម្មក្នុងតំបន់ ១ និងតំបន់ ២ ត្រូវហាមឃាត់

**មាត្រា ២៣ .-**

ក្នុងតំបន់១ អ.ជ.ព.វ ត្រូវ ៖

- រៀបចំបង្ហាញសភាពដើមពិតនៃបុរាណវិទ្យា ដោយរៀបចំទេសភាពឲ្យមានលក្ខណៈសមស្របតាមបុរាណវិទ្យា។

- ចាត់ចែងរៀបចំទេសភាពនៅជុំវិញប្រាសាទ តាមប្លង់គោលនៃគម្រោងរៀបចំអភិរក្ស និងអភិវឌ្ឍន៍តំបន់មានប្រាសាទ។

**មាត្រា ២៤ .-**

ក្នុងតំបន់ ២ អ.ជ.ព.វ ត្រូវរក្សា និងបង្កើតព្រៃទ្រនាប់ ដោយរៀបចំគម្រោងដាំដើមឈើឡើងវិញ។

**មាត្រា ២៥ .-**

ក្នុងតំបន់ ៣ និង ៤ អ.ជ.ព.វ ត្រូវការពារ លើកស្ទួយតម្លៃទេសភាពតាមរយៈការបង្កើតសកម្មភាពបរិស្ថាន កសិកម្ម និងការរៀបចំដែនដី ។

**មាត្រា ២៦ .-**

ក្នុងការចាត់ចែង គ្រប់គ្រងប្រភព និងធនធានទឹកនៅរមណីយដ្ឋានប្រាសាទព្រះវិហារ ក្នុងតំបន់ទាំង៤ អ.ជ.ព.វ ត្រូវជួសជុលដោយផ្អែកៗនូវរចនាសម្ព័ន្ធធារាសាស្ត្របុរាណ និងចាត់ចែងរបបគ្រប់គ្រងទឹកតាមសំណង់ធារាសាស្ត្រថ្មីឲ្យមានប្រសិទ្ធភាព។

**មាត្រា ២៧ .-**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ ត្រូវ៖

- ថែរក្សា និងស្តារបារាយណ៍ ស្រះបុរាណ អូរធម្មជាតិដែលមានស្រាប់ និងបរិស្ថានជុំវិញ។

- សិក្សា និងរកលទ្ធភាពក្នុងការស្តារ ដើម្បីអោយដំណើរការឡើងវិញនូវបារាយណ៍ ស្រះបុរាណ និងប្រព័ន្ធផ្លូវទឹកបុរាណ។

- ក្នុងករណីចាំបាច់ អ.ជ.ព.វ អាចរៀបចំជាតំបន់ដីអាចលើកគំរោងផែនការពិសេសសំរាប់ការស្តារ ប្រព័ន្ធធារាសាស្ត្រក្នុងគោលដៅបំរើឲ្យការអភិរក្ស កសិកម្ម ទេសចរណ៍ និងរក្សាលំនឹងការប្រែប្រួល អាកាសធាតុ។

**មាត្រា ២៨ .-**

ក្នុងតំបន់ ៣ និងតំបន់ ៤ អ.ជ.ព.វ អាចអនុញ្ញាតឲ្យមានការអភិវឌ្ឍធារាសាស្ត្រតូចៗដើម្បី បង្កើន ផលិតផលកសិកម្ម និងដើម្បីការប្រើប្រាស់ផ្ទាល់របស់អ្នករស់នៅទីនោះដោយមិនធ្វើឲ្យប៉ះពាល់ដល់ បរិស្ថាន និងបុរាណវត្ថុ។

## ជំពូកទី ៨

## ការចាត់ចែងគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា ២៩ .-**

រាល់ការចាត់ចែងគ្រប់គ្រងធនធានធម្មជាតិនៅរមណីយដ្ឋានប្រាសាទព្រះវិហារក្នុងតំបន់ទាំង៤ អ.ជ.ព.វ ត្រូវគ្រប់គ្រងទឹក ព្រៃឈើ សត្វព្រៃ និងធនធានក្រោមដី ដើម្បីថែរក្សា និងបង្កើនជីវចំរុះដោយ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៣០ .-**

ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ៖

- ថែរក្សា និងដាំឡើងវិញ នូវព្រៃឈើធម្មជាតិ ទឹក និង ដីព្រៃឈើ

- ថែទាំ ដាំដើមឈើនៅជុំវិញប្រាសាទ និងដកចេញដើមឈើដែលប៉ះពាល់ដល់សោភ័ណភាព ឬអាចបំផ្លាញដល់ប្រាង្គប្រាសាទ។

**មាត្រា ៣១ .-**

ក្នុងតំបន់ ២ និងតំបន់ ៣ អ.ជ.ព.វ ត្រូវ ៖

- បង្កើតសួនរុក្ខជាតិ និងផ្លូវលំតាមដងព្រៃ

- អនុវត្តកម្មវិធីដាំដើមឈើ ដែលមានពូជនៅក្នុងតំបន់។

## ជំពូកទី ៩

## ប្រជាជន

**មាត្រា ៣២ .-**

អ.ជ.ព.វត្រូវផ្តល់អាទិភាពការងារដល់ប្រជាជនរស់នៅក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារដើម្បី ចូលរួមចំណែកថែរក្សា និងលើកតម្លៃរមណីយដ្ឋានប្រាសាទព្រះវិហារ។

**មាត្រា ៣៣ .-**

ក្នុងតំបន់១ និងតំបន់ ២ អ.ជ.ព.វ មិនត្រូវអនុញ្ញាតឲ្យមានការបង្កើតភូមិ ឬការតាំងទីលំនៅឡើងវិញ។

**មាត្រា ៣៤ .-**

ក្នុងតំបន់ ៣ និងតំបន់ ៤ អ.ជ.ព.វ ត្រូវបង្កលក្ខណៈងាយស្រួល ជួយជំរុញ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋឲ្យបង្ករបង្កើនផលកសិកម្ម បង្កើតមុខរបរ ដើម្បីលើកកំពស់ជីវភាពរស់នៅរបស់ខ្លួន។

## ផ្នែកទី ១១

## អំពីវត្តអារាម

**មាត្រា ៣៥ .-**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ មិនត្រូវអនុញ្ញាតឲ្យមានវត្តអារាម ឬទីតាំងសាសនាផ្សេងៗទេ លើកលែងតែវត្តកែវសិក្ខាគិរីស្វរៈ។

**មាត្រា ៣៦ .-**

ក្នុងតំបន់ ៣ និងតំបន់ ៤ ការបង្កើតវត្តថ្មីនៅតាមភូមិនានាត្រូវគោរពតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

## ផ្នែកទី ១២

## អំពីសិប្បកម្ម និងសេវាកម្ម

**មាត្រា ៣៧ .-**

- មិនត្រូវអនុញ្ញាតឲ្យមានការអភិវឌ្ឍឧស្សាហកម្មក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ លើកលែងតែសិប្បកម្ម ឬសេវាកម្មមានទ្រង់ទ្រាយតូចៗបម្រើឲ្យការអភិរក្ស កសិកម្ម និងទេសចរណ៍។
- ត្រូវគ្រប់គ្រងឲ្យបានត្រឹមត្រូវរាល់សំណល់រឹង និងរាវបង្កើតឡើងដោយសិប្បកម្ម និងសេវាកម្ម។

**មាត្រា ៣៨ .-**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ ត្រូវកំណត់ទីតាំង ទំហំ និងចំនួនតូបលក់ដូរវត្ថុទាំងឡាយឲ្យមានគុណភាព និងរក្សាតម្លៃរមណីយដ្ឋានវប្បធម៌។

## ផ្នែកទី ១៣

## អំពីបណ្តាញចរន្តអគ្គិសនី

**មាត្រា ៣៩ .-**

ក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ អ.ជ.ព.វ ត្រូវ ៖

- អនុញ្ញាតឲ្យដាក់បណ្ដាញចរន្តអគ្គិសនី ដែលផ្ដល់អគ្គិសនីដល់មូលដ្ឋាននោះ ដោយរក្សាសោភ័ណភាពធម្មជាតិ។

- គ្រប់គ្រងរាល់ការតុបតែង និងការរៀបចំពិធីផ្សេងៗក្នុងតំបន់ ដោយត្រូវអនុវត្តតាមលក្ខណៈបច្ចេកទេស។

## ផ្នែកទី ១៤

## ការទាក់ទាញអារម្មណ៍ចំពោះបរិស្ថាន

**មាត្រា ៤០ .-**

ក្នុងតំបន់ទាំង៤ អ.ជ.ព.វ ត្រូវផ្ដើមអនុវត្តកម្មវិធី ដើម្បីឲ្យមានការទាក់ទាញអារម្មណ៍ប្រជាជនមូលដ្ឋាន និងទស្សនិកជនចំពោះសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ធម្មជាតិ និងចំពោះបញ្ហាបរិស្ថាន។

**មាត្រា ៤១ .-**

ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវៈ

- កំណត់ទីតាំង និងរៀបចំតូបលក់ដូរវត្ថុអនុស្សាវរីយ៍ ទីតាំងសេវាចាំបាច់គ្រប់ប្រភេទតាមរចនាបថខ្មែរ

- កំណត់ទីតាំង និងរៀបចំឲ្យមានបង្គន់អនាម័យ ធុងដាក់សំរាមឲ្យបានត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស។

## ផ្នែកទី ១៥

## អំពីធនធានមនុស្ស

**មាត្រា ៤២ .-**

អ.ជ.ព.វ ត្រូវ ៖

- បណ្ដុះបណ្ដាលអ្នកជំនាញសម្រាប់ការដ្ឋានកំណាយ និងការងារអភិរក្ស។

- បណ្ដុះបណ្ដាលមគ្គុទេសក៍ទេសចរណ៍ ឆ្មាំឧទ្យាន និងបុគ្គលិកថែទាំ ផ្ដល់កិច្ចសហប្រតិបត្តិការជាមួយបុរាណវិទូ ស្ថាបត្យករ និងអ្នកប្រកបវិជ្ជាជីវៈផ្សេងៗទៀតក្នុងផ្នែកចាត់ចែងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ធម្មជាតិ។

- សហការជាមួយស្ថាប័ន និងអង្គការជាតិ និងអន្តរជាតិដើម្បីបណ្ដុះបណ្ដាលមន្ត្រីជំនាញគ្រប់កំរិត។

- យកចិត្តទុកដាក់ដល់ប្រជាជនក្នុងតំបន់ ដើម្បីរក្សានិរន្តរភាពក្នុងការការពារ និងការអភិវឌ្ឍប្រកបដោយចីរភាព ។

- លើកទឹកចិត្ត និងបណ្តុះបណ្តាលប្រជាជនឲ្យមានមុខជំនាញទូទៅក្នុងផ្នែកកសិកម្ម បរិស្ថាន និងទេសចរណ៍។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៤៣ .-**

អនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រធានអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

លេខ ១០៥ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក ៖

.ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ដើម្បីជូនជ្រាប"

.ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

.លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត "ដើម្បីជ្រាប"

រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៤

ត.ប រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គលេខាធិការ